ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខៈ បព ៤០/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃដំណើរទស្សនកិច្ចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅប្រទេសអូស្ត្រាលី

តបតាមការអញ្ជើញរបស់ **លោកជំទាវ ផេននី វ៉ង** រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសអូស្ត្រាលី ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦។

ក្នុងឱកាសទស្សនកិច្ច **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលជួបសម្តែងការគួរសមចំពោះ **ឯកឧត្តម មីលតុន឴ ឌិក** ប្រធានរដ្ឋសភាអូស្ត្រាលី និងមានជំនួបដាច់ដោយឡែកជាមួយ**លោកជំទាវ ផេននី វ៉ង** និង**ឯកឧត្តម រីឆាត ម៉ាលស៍** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ។ ជំនួបទាំងនេះ បានផ្តល់ឱកាសដ៏ល្អសម្រាប់ភាគីទាំងពីរ ដើម្បីពិនិត្យឡើងវិញអំពីវឌ្ឍនភាពនៃទំនាក់ទំនងកម្ពុជា-អូស្ត្រាលី និងស្វែងរកមធ្យោបាយនានាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែមទៀត។

## កិច្ចសហប្រតិបត្តិការនយោបាយ និងស្ថាប័ននីតិប្បញ្ញត្តិ

ថ្នាក់ដឹកនាំអូស្ត្រាលីបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងបានបញ្ជាក់ជាថ្មីពីចំណងមិត្តភាពយូរអង្វែងរវាងកម្ពុជា និងអូស្ត្រាលី។ ភាគីទាំងពីរគូសបញ្ជាក់ពីសារៈសំខាន់នៃការបន្តផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ជាទៀងទាត់ និងការពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ រួមទាំងការជំរុញការទូតសភា។

## កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច

ភាគីទាំងពីរបានស្វាគមន៍ចំពោះកំណើនទំហំពាណិជ្ជកម្មទ្វេភាគី និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅប៉ុន្មានឆ្នាំចុងក្រោយនេះ និងទទួលស្គាល់ថា នៅមានសក្តានុពលជាច្រើនសម្រាប់ការពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត។ អូស្ត្រាលីនៅតែជាដៃគូសេដ្ឋកិច្ចដ៏សំខាន់សម្រាប់កម្ពុជា ដែលមានទំហំពាណិជ្ជកម្មទ្វេភាគីប្រមាណ ១,២ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥។ **ឯកឧត្តម ប្រាក់ សុខុន** បានលើកទឹកចិត្តឱ្យធុរជនអូស្ត្រាលី ស្វែងរកឱកាសវិនិយោគនៅកម្ពុជា លើវិស័យអាទិភាពនានាដូចជា អប់រំ កសិកម្ម ការកែច្នៃផលិតផលកសិកម្ម ថាមពល រ៉ែ និងសេវាសុខាភិបាល។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការអភិវឌ្ឍមូលធនមនុស្ស

**ឯកឧត្តម ប្រាក់ សុខុន** បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអូស្ត្រាលី សម្រាប់ការផ្តល់ជំនួយអភិវឌ្ឍន៍យូរអង្វែងដល់កម្ពុជា ដែលបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ដល់ការស្តារកម្ពុជាឡើងវិញក្រោយសង្គ្រាម និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់អូស្ត្រាលី រួមមាន ការគាំទ្រក្នុងវិស័យកសិកម្ម អប់រំ សុខាភិបាល និងការបោសសម្អាតមីន មានទឹកប្រាក់សរុបប្រមាណ ១,៤ ប៊ីលានដុល្លារអាមេរិក ចាប់តាំងពីឆ្នាំ១៩៩២ មក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានទទួលស្គាល់ការបន្តគាំទ្ររបស់អូស្ត្រាលី ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមរយៈអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលី (Australia Awards Scholarships) ដែលបាននិងកំពុងផ្តល់ឱកាសឱ្យនិស្សិតកម្ពុជាជាង ១.១០០ នាក់ បន្តការសិក្សាថ្នាក់ក្រោយឧត្តមសិក្សានៅប្រទេសអូស្ត្រាលី។

## កិច្ចសហប្រតិបត្តិការសន្តិសុខ និងការពារជាតិ

នៅក្នុងជំនួបជាមួយ**ឯកឧត្តម រីឆាត ម៉ាលស៍** ភាគីទាំងពីរបានពិភាក្សាពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការសន្តិសុខ និងការពារជាតិរវាងប្រទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់ពីកិច្ចសហប្រតិបត្តិការដែលកំពុងបន្តក្នុងវិស័យនានារួមមាន ការប្រយុទ្ធប្រឆាំងភេរវកម្ម ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការកសាងសមត្ថភាពការពារជាតិ។ ភាគីកម្ពុជាក៏បានសម្តែងអំណរគុណអូស្ត្រាលីចំពោះការបន្តគាំទ្រក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញសម្រាប់មន្ត្រីយោធាកម្ពុជា។

ពាក់ព័ន្ធនឹងសភាពការណ៍ព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានពិភាក្សាយ៉ាងស៊ីជម្រៅជាមួយថ្នាក់ដឹកនាំអូស្ត្រាលី អំពីការវិវត្តថ្មីៗ និងបានថ្លែងអំណរគុណអូស្ត្រាលីចំពោះការគាំទ្រដល់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី។

ក្នុងឱកាសបំពេញទស្សនកិច្ចនេះ **ឯកឧត្តម ប្រាក់ សុខុន** ក៏បានអញ្ជើញជួបសហគមន៍ខ្មែរ និងនិស្សិតកម្ពុជាដែលកំពុងរស់នៅ និងសិក្សានៅក្នុងប្រទេសអូស្ត្រាលី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះការចូលរួមដ៏មានអត្ថន័យរបស់ប្រជាពលរដ្ឋខ្មែរក្នុងសង្គមពហុវប្បធម៌របស់អូស្ត្រាលី។

**ឯកឧត្តម ប្រាក់ សុខុន** បានសម្តែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលអូស្ត្រាលី និង **លោកជំទាវ ផេននី វង** ដែលបានរៀបចំទទួលដ៏ល្អ និងផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងគណៈប្រតិភូកម្ពុជា ក្នុងអំឡុងពេលទស្សនកិច្ចនេះ។ ភាគីទាំងពីរបានសម្តែងនូវការជឿជាក់ថា ទស្សនកិច្ចនេះនឹងពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការផ្តល់ផលប្រយោជន៍ទៅវិញទៅមកបន្ថែមទៀតរវាងកម្ពុជា និងអូស្ត្រាលី។

ថ្ងៃចន្ទ ១៣ រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦